MEDIA STATEMENT

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# ហ្សេដ អំពាវនាវឲ្យរដ្ឋនានា "អនុវត្តជាក់ស្តែងឲ្យលើសពីអ្វីដែលខ្លួនបាននិយាយ ដើម្បីឈានទៅសម្រេចបាននូវសមភាពយេនឌ័រ" សម្រាប់ទិវាសិទ្ធិនារីអន្តរជាតិ ៨ មីនា ឆ្នាំ២០១៥

ទីក្រុងហ្សឺណែវ (៥ មីនា ២០១៥) - ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស ហ្សេដ រ៉ាអាដ អាល ហ៊ូហ្សេន (Zeid Ra'ad Al Hussein) បានគូសបញ្ជាក់ នៅថ្ងៃនេះ ថា៖ "សេចក្តីត្រូវការបន្ទាន់គឺដើម្បីឲ្យស្រ្តីអាចចូលរួមក្នុងរាល់កិច្ចពិភាក្សាទាំងអស់អំពីការឆ្លើយតបជាយុទ្ធសាស្រ្តទៅនឹងអំពើហិង្សារបស់ពួកជ្រុលនិយម ការរើសអើង និងការដកហូតសិទ្ធិគ្រប់យ៉ាង។"

លោកបានមានប្រសាសន៍ថា "ឆ្នាំនេះគឺជាខួបលើកទី២០ នៃសេចក្តីប្រកាស និងកម្មវិធីសកម្មភាពក្រុងប៉េកាំង។ រដ្ឋនានាអាចយកឱកាសនេះ អនុវត្តជាក់ស្តែងឲ្យលើសពីអ្វីដែលខ្លួនបាននិយាយ និងឈានទៅសម្រេចបាននូវសមភាពយេនឌ័រ - ដែលជាបញ្ហាត្រូវប្រឈមពិតប្រាកដ និងការលុបបំបាត់បន្តិចម្តងៗនូវរចនាសម្ព័ន្ធអំណាច និងថាមវ័ន្ត ដែលធ្វើឲ្យកើតមានមិនចេះឈប់ឈរនូវការរើសអើងប្រឆាំងនឹងស្រ្តីភេទ។"

"នៅគ្រប់ទិសទីក្នុងពិភពលោក មានការងារជាច្រើន ដែលគេអាចធ្វើបាន ដើម្បីធានាការពារ និងគាំទ្រសិទ្ធិស្រ្តី សិទ្ធិទទួលបានការងារ និងមុខរបរ សិទ្ធិសុខភាព - និងសមត្ថភាពរបស់ស្រ្តីក្នុងការគ្រប់គ្រងលើការធ្វើសេចក្តីសម្រេចទាំងឡាយ ដែលទាក់ទងនឹងចំណុចណាមួយនៃជីវិតរស់នៅរបស់ខ្លួន។"

ហ្សេដ បានសំដែងការគោរពដល់ស្រ្តីអ្នកការពារសិទ្ធិមនុស្សនៅគ្រប់ទិសទី ដោយបានសាទរសេចក្តីក្លាហានរបស់ពួកគេ នៅក្នុងស្ថានភាពដែលប្រឈមនឹងឧបសគ្គទាំងឡាយដ៏សែនលំបាក និងគ្រោះថ្នាក់។

លោកបានមានប្រសាសន៍ថា "ការផ្លាស់ប្តូរពិតប្រាកដ អាចនឹងកើតឡើងបាន លុះត្រាតែ ស្រ្តី និងបុរស រួមគ្នាប្រយុទ្ធទាមទារសិទ្ធិទាំងនេះ - ហើយស្រ្តីអ្នកការពារសិទ្ធិមនុស្ស បាន និងកំពុងស្ថិតនៅជួរមុខនៃការប្រយុទ្ធទាមទារនេះ លោកបានបន្តទៀតថា "យើងទាំងអស់គ្នា រួមមាន បុរស ស្រ្តី កុមារា កុមារី - ត្រូវរួមគ្នាខិតខំប្រឹងប្រែង ដើម្បីលុបបំបាត់ការរើសអើងយេនឌ័រ។ ចូរយើងសម្រេចវាឲ្យបាន។"

*សូមមើលវីដេអូរបស់ឧត្តមស្នងការស្តីពីស្រ្តីអ្នកការពារសិទ្ធិមនុស្ស៖*
*https://www.youtube.com/watch?v=gchsVUZ5GOg*

*ចូលរួមជាមួយយុទ្ធនាការ #reflect2protect របស់ការិយាល័យសិទ្ធិមនុស្ស អ.ស.ប តាមរយៈការថតជាលក្ខណៈសែលហ្វី (selfie) និងបង្ហោះវានៅតាមបណ្តាញសង្គម ដោយប្រើសញ្ញាសម្គាល់ ឬអក្សរកាត់ខ្លីៗខាងលើ។ សូមមើលវីដេអូអំពី ការប្រកាសបើកយុទ្ធនាការនេះតាមរយៈ៖*
*https://www.youtube.com/watch?v=2xrHxAaTw7w&t=103*

*#MakeItHappen គឺជាប្រធានបទផ្លូវការសម្រាប់ទិវាសិទ្ធិនារីអន្តរជាតិ ឆ្នាំ២០១៥។ សូមប្រើប្រាស់ សញ្ញាសម្គាល់ ឬអក្សរកាត់ខ្លីៗ ដើម្បីប្រារព្ធទិវានេះ។*

*ចប់*

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមមេត្តាទាក់ទងមក៖ រ៉ូភឺត ខូលវីល (Rupert Colvile) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៧៦៧ / rcolville@ohchr.org) ឬ រ៉ាវីណា ស៊ើមដាសានី (Ravina Shamdasani) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩១៦៩/ rshamdasani@ohchr.org) ឬ សេសីល ពូអ៊ីលលី (Cécile Pouilly តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣១០ / cpouilly@ohchr.org)*

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈបណ្ដាញព័ត៌មានសង្គម ៖**

**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights

**ទ្វីតធឺ៖** http://twitter.com/UNrightswire

**ហ្គោហ្គិល៖** Google+ gplus.to/unitednationshumanrights

**យូធូប៖** http://www.youtube.com/UNOHCHR

**បរិយាយសាច់រឿង៖** http://storify.com/UNrightswire

**ផែនកមើលលិបិក្រមសិទ្ធិមនុស្សជាសកល៖** http://uhri.ohchr.org/en